**សូមឈប់ និងពិនិត្យម្តងទៀត ថាតើនេះជាព័ត៌មានត្រឹមត្រូវសម្រាប់អ្នកឬទេ!** KHMER

សន្លឹកព័ត៌មាននេះសម្រាប់តែអ្នកបោះឆ្នោតនៅក្នុងតំបន់ Amador, Butte, Calaveras, El Dorado, Fresno, Los Angeles, Madera, Mariposa, Napa, Nevada, Orange, Sacramento, San Mateo, Santa Clara និងតំបន់ Tuolumne ប៉ុណ្ណោះ។

# ស្គាល់សិទ្ធិបោះឆ្នោតរបស់អ្នក

ASIAN AMERICANS ADVANCING JUSTICE
ASIAN LAW CAUCUS

## ត្រៀមខ្លួនដើម្បីបោះឆ្នោត

ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតណាមួយ ជាដំបូង អ្នកត្រូវចុះឈ្មោះដើម្បីបោះឆ្នោតជាមុនសិន! អ្នកអាចចុះឈ្មោះ
បោះឆ្នោតបាន ប្រសិនបើអ្នកជា៖

- ពលរដ្ឋអាមេរិក
- អ្នកស្រុកនៃរដ្ឋកាលីហ្វ័រញ៉ា
- នឹងមានអាយុ ១៨ ឆ្នាំ ឬច្រើនជាងនេះនៅថ្ងៃបោះឆ្នោត
- បច្ចុប្បន្នមិនជាប់ពន្ធនាគារ ឬស្ថិតក្រោមការដោះលែងជាបណ្តោះអាសន្នក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ និង
- មិនត្រូវបានរកឃើញដោយតុលាការថា "ខ្វះសមត្ថភាពផ្នែកស្មារតី។"

### ចុះឈ្មោះរួចហើយ?

ពិនិត្យ និងបញ្ជាក់ព័ត៌មានស្តីពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក។ ប្រើ voterstatus.sos.ca.gov ដើម្បី៖

- បញ្ជាក់អាសយដ្ឋានផ្ញើសាររបស់អ្នក
- បន្ថែម ឬបញ្ជាក់អាសយដ្ឋានអ៊ីម៉ែលណាមួយ ដើម្បីទទួលបានព័ត៌មានឱ្យទាន់ពេលវេលាពីការិយាល័យបោះឆ្នោតតំបន់របស់អ្នក
- បង្ហាញភាសាជាចំណង់ចំណូលចិត្តរបស់អ្នក ដើម្បីទទួលបានឯកសារដែលបកប្រែរួច ប្រសិនបើមាននៅក្នុងតំបន់របស់អ្នក។

### ចង់ចុះឈ្មោះ?

ដល់ថ្ងៃច័ន្ទ ទី 19 ខែតុលា អ្នកអាចចុះឈ្មោះ៖

- តាមអ៊ីធើណិត តាមរយៈ registertovote.ca.gov
- នៅ DMV, ការិយាល័យប៉ុស្តិ៍, បណ្ណាល័យ ឬការិយាល័យបោះឆ្នោតរបស់អ្នក ឬ
- តាមរយៈការហៅទូរស័ព្ទ (800) 345-8683 ដើម្បីស្នើសុំពាក្យសុំចុះឈ្មោះបោះឆ្នោត ដែលត្រូវតែផ្ញើទៅប្រៃសណីយ៍ ត្រឹមថ្ងៃទី១៩ ខែតុលា។ មិនត្រូវការត្រាទេ!

### ចុះបើខ្ញុំខកខានកាលកំណត់ចុះឈ្មោះរបស់អ្នកបោះឆ្នោត?

គ្មានបញ្ហា! អ្នកនៅតែអាចចុះឈ្មោះ និងបោះឆ្នោតនៅថ្ងៃណាមួយរហូតដល់ និងរួមទាំងថ្ងៃបោះឆ្នោត។

| | |
|---|---|
| ជម្រើស 1៖ | អ្នកអាចចូលទៅកាន់ការិយាល័យបោះឆ្នោតតំបន់របស់អ្នក ឬមណ្ឌលបោះឆ្នោតណាមួយនៅក្នុងតំបន់របស់អ្នក ដើម្បីប្រើ "ការចុះឈ្មោះបោះឆ្នោតនៅថ្ងៃតែមួយ" ដើម្បីចុះឈ្មោះ និងបោះឆ្នោតនៅពេលនោះ។ អ្នកនឹងទទួលបានពាក្យសុំចុះឈ្មោះរបស់អ្នកបោះឆ្នោត និងសន្លឹកឆ្នោត ដើម្បីបំពេញនៅនឹងកន្លែង។ |
| ជម្រើស 2៖ | ប្រសិនបើអ្នកមិនត្រូវបានចុះឈ្មោះបោះឆ្នោត និងមិនអាចទៅទីតាំងបោះឆ្នោតបាន សូមទំនាក់ទំនងការិយាល័យបោះឆ្នោតតំបន់របស់អ្នក ដើម្បីសួរអំពីរបៀបដែលអ្នកអាចចុះឈ្មោះ និងបោះឆ្នោតពីចម្ងាយ ដោយប្រើ "ការបោះឆ្នោតដែលអាចប្រើបានពីចម្ងាយតាមរយៈប្រៃសណីយ៍។" |

## ការបោះឆ្នោតទូទៅឆ្នាំ 2020 របស់រដ្ឋកាលីហ្វូញ៉ា

| | |
|---|---|
| ចាប់ពីថ្ងៃទី 5 ខែតុលា ឆ្នាំ 2020 | សន្លឹកឆ្នោតដែលបានផ្ញើទៅអ្នកបោះឆ្នោតទាំងអស់ដែលបានចុះឈ្មោះរួច |
| ថ្ងៃអង្គារ ទី 6 ខែតុលា ឆ្នាំ 2020 | ប្រអប់ដាក់សន្លឹកឆ្នោត បើក៖ |
| ថ្ងៃច័ន្ទ ទី 19 ខែតុលា ឆ្នាំ 2020 | កាលផុតកំណត់នៃការចុះឈ្មោះ |
| ថ្ងៃសៅរ៍ ទី 31 ខែតុលា ឆ្នាំ 2020 - ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020 | មណ្ឌលបោះឆ្នោតដោយផ្ទាល់៖ (អាចបើកមុនពេលកំណត់នៅក្នុងតំបន់មួយចំនួន!) |

## បោះឆ្នោតដោយរបៀបណា? អ្នកមានជម្រើសជាច្រើន!

### បោះឆ្នោតពីផ្ទះ

ប្រសិនបើអ្នកចុះឈ្មោះត្រឹមថ្ងៃទី 19 ខែតុលា អ្នកនឹងទទួលបានដោយស្វ័យប្រវត្តិនូវសន្លឹកឆ្នោតនៅក្នុងប្រៃសណីយ៍ ដោយមានការណែនាំអំពីរបៀបបំពេញនិងបញ្ជូនសន្លឹកឆ្នោតមកវិញ។ អ្នកអាច៖

- ផ្ញើសន្លឹកឆ្នោតរបស់អ្នកតាមប្រៃសណីយ៍ -- មិនត្រូវការត្រា!
  - ចូលចងចាំថាត្រូវចុះហត្ថលេខា និងកាលបរិច្ឆេទប្រអប់សំបុត្រសន្លឹកឆ្នោតរបស់អ្នក។
  - ត្រូវប្រាកដថាសន្លឹកឆ្នោតរបស់អ្នកមានត្រានៅថ្ងៃ ឬមុនថ្ងៃបោះឆ្នោត។
- ដាក់សន្លឹកឆ្នោតនៅប្រអប់សំបុត្រមួយក្នុងចំណោម "ប្រអប់ដាក់ឆ្នោត" ជាច្រើន ដែលស្ថិតនៅពេញតំបន់ ឬនៅមណ្ឌលបោះឆ្នោត -- សូមបញ្ជាក់ម្តងទៀត មិនត្រូវការត្រា!
  - ស្វែងរក "ប្រអប់ដាក់ឆ្នោត" ដែលនៅជិត និងមណ្ឌលបោះឆ្នោតនៅ caearlyvoting.sos.ca.gov.

### បោះឆ្នោតដោយផ្ទាល់

ប្រសិនបើអ្នកចង់បោះឆ្នោតដោយផ្ទាល់ អ្នកអាច!

អ្នកអាចបោះឆ្នោតនៅមណ្ឌលបោះឆ្នោតណាមួយនៅក្នុងតំបន់របស់អ្នក។ មណ្ឌលបោះឆ្នោតនឹងបើកចាប់ពីថ្ងៃសៅរ៍ ទី 31 ខែតុលា ឆ្នាំ 2020 ដល់ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ហើយមណ្ឌលមួយចំនួនអាចបើករយៈពេល 10 ថ្ងៃ មុនថ្ងៃបោះឆ្នោត។ អ្នកនឹងទទួលបានព័ត៌មានអំពីទីតាំងមណ្ឌលបោះឆ្នោត និងម៉ោងបោះឆ្នោតតាមប្រៃសណីយ៍ ឬអ្នកអាចពិនិត្យនៅទីនេះ៖ caearlyvoting.sos.ca.gov.

នៅថ្ងៃបោះឆ្នោត មណ្ឌលបោះឆ្នោតនឹងបើកចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់។ ដរាបណាអ្នកស្ថិតនៅក្នុងជួរមុនម៉ោង 8 យប់ អ្នកនឹងអាចបោះឆ្នោតរបស់អ្នកបាន។

ដើរចូលទៅក្នុងមណ្ឌលបោះឆ្នោតណាមួយ រួចហើយផ្តល់ឈ្មោះ និងអាសយដ្ឋានដើម្បីទទួលបានសន្លឹកឆ្នោត។ ប្រសិនបើអ្នកចង់បោះឆ្នោតជាភាសាណាមួយមិនមែនជាភាសាអង់គ្លេស សូមសួរថាតើពួកគេមានឯកសារណាមួយជាភាសានោះដែរឬទេ ហើយថាតើអ្នកធ្វើការនៅកន្លែងបោះឆ្នោតនិយាយភាសានោះដែរឬទេ។

### តើនឹងមានកិច្ចការពារសុខភាពសាធារណៈដែរឬទេ?

មាន។ បុគ្គលិកមណ្ឌលបោះឆ្នោតនឹងពាក់ម៉ាស់ និងធ្វើតាមគោលការណ៍ណែនាំស្តីពីសុខភាពសាធារណៈ និងបង្កើតកន្លែងបោះឆ្នោត ដើម្បីអនុញ្ញាតឱ្យមានការនៅឱ្យដាច់ឆ្ងាយពីគ្នា។ អ្នកបោះឆ្នោតត្រូវតែអនុលោមតាមលក្ខខណ្ឌតម្រូវស្តីពីសុខភាពសាធារណៈរបស់រដ្ឋ និងថ្នាក់មូលដ្ឋាន រួមមានការពាក់របាំងមុខ និងការរក្សាគម្លាតរាងកាយ។

### តើខ្ញុំអាចនាំនរណាម្នាក់ទៅជួយខ្ញុំបោះឆ្នោតបានទេ?

បាន។ ច្បាប់រដ្ឋកាលីហ្វូញ៉ាអនុញ្ញាតឱ្យអ្នកនាំមនុស្សបានពីរនាក់ដើម្បីជួយបោះឆ្នោតដោយផ្ទាល់ ដរាបណាពួកគេមិនតំណាងនិយោជករបស់អ្នក ឬសហជីពរបស់អ្នក។ សូមនាំសមាជិកគ្រួសារ ឬមិត្តភក្តិ។

### តើខ្ញុំចាំបាច់ត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំនៅពេលបោះឆ្នោតដែរឬទេ?

ស្ទើរតែគ្រប់ស្ថានភាពទាំងអស់ មិនចាំបាច់ទេ។ អ្នកគ្រាន់តែបង្ហាញឯកសារ ប្រសិនបើអ្នកបោះឆ្នោតជាលើកទីមួយ និងប្រសិនបើអ្នកមិនបានបញ្ចូលលេខអាជ្ញាប័ណ្ណបើកបរ លេខអត្តសញ្ញាណប័ណ្ណរដ្ឋ ឬលេខសន្តិសុខសង្គម (លេខសូសាល់) នៅពេលដែលអ្នកចុះឈ្មោះបោះឆ្នោត។ ប្រសិនបើមានករណីបែបនេះ ឯកសារច្រើនអាចប្រើការបាន។ សូមហៅទូរសព្ទទៅកាន់មន្ត្រីបោះឆ្នោតរបស់អ្នកជាមុន ប្រសិនបើអ្នកមានក្តីបារម្ភ។

### ចុះបើខ្ញុំមានបញ្ហានៅពេលកំពុងបោះឆ្នោត?

សូមកុំបោះបង់! សូមស្នើសុំប្រើការចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃតែមួយ ដើម្បីចុះឈ្មោះឡើងវិញ និងបោះឆ្នោត។ ប្រសិនបើអ្នកមិនអាចធ្វើបែបហ្នឹងបាន ដោយសារហេតុផលណាមួយ សូមស្នើសុំសន្លឹកឆ្នោតបណ្តោះអាសន្ន ជាសន្លឹកឆ្នោតដែលនឹងត្រូវបានរាប់ក្រោយថ្ងៃបោះឆ្នោត ប្រសិនបើមន្ត្រីបោះឆ្នោតបញ្ជាក់លក្ខខណ្ឌគ្រប់គ្រាន់របស់អ្នក។

ឬ ហៅទូរសព្ទទៅកាន់លេខទាន់ហេតុការណ៍នៃកិច្ចការពារអ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោត មួយក្នុងចំណោមលេខទាំងនោះ៖

- 866-687-8683 សម្រាប់ជំនួយជាភាសាអង់គ្លេស។
- 888-274-8683 សម្រាប់ជាភាសាអង់គ្លេស, ចិន, ចិនកាតាំង, វៀតណាម, កូរ៉េ, បង់ហ្គា, អ៊ឺឌូ, ហិណ្ឌូ និង តាហ្គាឡុក ។
- 888-839-8682 សម្រាប់ជំនួយជាភាសាអង់គ្លេស និងអេស្ប៉ាញ ដោយមិនគិតថ្លៃ។

## តើខ្ញុំនឹងអាចបោះឆ្នោតជាភាសាណាមួយក្រៅពីភាសាអង់គ្លេសបានទេ?

ជំនួយផ្នែកភាសាខុសគ្នាទៅតាមតំបន់។ សូមហៅទូរសព្ទទៅកាន់ការិយាល័យបោះឆ្នោតតំបន់របស់អ្នក ឬទៅកាន់មណ្ឌលបោះឆ្នោត ដើម្បីសួរថាតើមានឯកសារដែលបកប្រែរួចហើយដែរឬទេ និងថាតើបុគ្គលិកដែលវត្តមាននិយាយភាសាដែលអ្នកចង់បានដែរឬទេ។

ភាសាដែលអាចផ្តល់ជូននៅក្នុងតំបន់របស់អ្នក រួមមាន៖ អារ៉ាប់, អាមេនី, បង់ហ្គា, ភូមា, ចិន, ហ្វាស៊ី, ហ្គូចារ៉ាទី, ហិណ្ឌូ, ម៉ុង, អ៊ីឡូកាណូ, ឥណ្ឌូនេស៊ី, ជប៉ុន, ខ្មែរ, កូរ៉េ, ឡាវ, មៀន, ម៉ុងហ្គោលី, នេប៉ាល់, ប៉ុនចា, អេស្ប៉ាញ, ស៊ីរី, តាហ្គាឡុក, តាមិល, តេលូហ្គូ, ថៃ, អ៊ីឌូ និងវៀតណាម។

អ្នកអាចស្វែងរកឯកសារចែកជូនស្តីពីភាសាដែលអាចប្រើបាននៅក្នុងការបោះឆ្នោត ដែលពន្យល់អំពីភាសាអ្វីខ្លះនៅក្នុងតំបន់របស់អ្នក៖ advancingjustice-alc.org/know-your-voting-rights.